# ការយកពុម្ព



ជំហានដំបូង គឺការជ្រើសរើសប្រដាប់យកពុម្ពធ្មេញ (Impression Tray) ដែលត្រឹមត្រូវដើម្បីដាក់ម្សៅសំរាប់ខាំពុម្ព។ ប្រភេទជាចំបងពីរនោះ គឺសំរាប់អ្នកជំងឺដែលមានធ្មេញ(**Dentate**)និងអ្នកជំងឺដែលគ្មានធ្មេញ(**Edentulous**)។ ចំពោះអ្នកជំងឺដែលមានធ្មេញ យើងប្រើប្រដាប់យកពុម្ពដែលមានរាងដូចប្រអប់ដែលនឹងគ្របលើធ្មេញដែលនៅមានដើម្បីអោយម្សៅខាំពុម្ពសាយភាយស្មើសាច់



ចំពោះអ្នកជំងឺដែលមិនមានធ្មេញ យើងប្រើប្រដាប់យកពុម្ព ដែលមានរាងកោង ដើម្បីគ្របលើគែមឆ្អឹងក្រអូម។



ប្រដាប់យកពុម្ព អាចជាប្រដាប់យកពុម្ពប្លាស្ទិកប្រើហើយចោល ដែលមានដង រឺ ប្រដាប់យកពុម្ពលោហៈ ក្រុមហ៊ុនផលិតផ្សេងៗគ្នា មានរូបរាងខុសៗគ្នាតិចតួចដែរ។ នៅពេលដែល ប្រដាប់យកពុម្ពដែលសក្តិសម បានជ្រើសរើសរួចហើយ វាត្រូវបាន ល ក្នុងមាត់អ្នកជំងឺ ដើម្បីពិនិត្យមើលភាពអិបល្អរបស់វា។ គែមរបស់ប្រដាប់យកពុម្ពអាចធ្វើឱ្យកាន់តែត្រូវល្អដោយកំដៅ Greenstick composite ហើយរំលាយខ្លះដាក់លើគែមរបស់ប្រដាប់យកពុម្ព។ ប្រដាប់យកពុម្ពគួរតែដាក់ចូលក្នុងចានទឹកមុននឹង ល ក្នុងមាត់អ្នកជំងឺ ដើម្បីធានាឱ្យច្បាស់ថា Greenstick មិនធ្វើឱ្យរលាកអ្នកជំងឺ។ ក្រមួនបន្ទះពណ៌ក្រហម ក៏អាចប្រើបានដែរ។











បន្ទាប់ពីការយកពុម្ពដំបូងត្រូវបានធ្វើរួច ត្រូវចាក់វាចេញជា model ពី plaster ឬ stone ហើយប្រដាប់យកពុម្ពជាពិសេស រឺ ប្រដាប់យកពុម្ពសំរាប់មនុស្សម្នាក់ៗ (special or individual tray) ត្រូវបានធ្វើឡើងដើម្បីអោយអិបយ៉ាងច្បាស់លាស់ទៅនឹងមាត់អ្នកជំងឺ។

អាស្រ័យលើម្សៅខាំពុម្ពដែលនឹងត្រូវយកមកប្រើសំរាប់ ពុម្ពធ្មេញចុងក្រោយ រឺ ពុម្ពធ្មេញធ្វើជាគោលអ្នកបច្ចេកទេសខាង labo នឹងបង្កើតប្រដាប់យកពុម្ព ដែលអិបនឹង model យ៉ាងល្អ ឬ ក៏មានចន្លោះ 2-3mm។ គោលបំណងនៃការយកពុម្ពចុងក្រោយ គឺដើម្បីទទួលបានកំរាស់ស្មើសាច់ នៃម្សៅខាំពុម្ពពាសពេញមាត់ដើម្បីធានានូវលំនឹង និង ការយកពុម្ពដែលត្រឹមត្រូវច្បាស់លាស់។

**ម្សៅខាំពុម្ពៈ**

ម្សៅខាំពុម្ព ត្រូវតែចំលងនូវភាពល្អិតល្អន់របស់មាត់ ដូចនេះ ការចាក់ពុម្ព រឺ model អាចត្រូវបានបង្កើតឡើងពីរូបរាងរបស់មាត់។ Model អាចគ្រាន់តែត្រូវការដើម្បីធ្វើការត្រួតពិនិត្យភាពល្អិតល្អន់របស់ធ្មេញ និងទំនាក់ទំនងរវាងធ្មេញនិងធ្មេញ ឬ វាអាចគេត្រូវការ សំរាប់ដំណាក់កាលក្នុងការផលិត ឧបករណ៍ពាក់ក្នុងមាត់ រឺ ធ្មេញសិ្ទតដើម្បីឱ្យអិបនឹងមាត់។

ម្សៅខាំពុម្ពៈ

ត្រូវតែមានភាពយឺតដើម្បីអោយអាចហូរជុំវិញធ្មេញ ហើយនៅពេលរឹងអាចទាញយកចេញពីធ្មេញ ហើយនៅតែរក្សារូបរាងដដែល។

ត្រូវតែច្បាស់ល្អ និងចំលងនូវរាល់ភាពលំអិតតូចៗទាំងអស់

ត្រូវតែមិនខាប់ខ្លាំងពេក ដែលវាសង្កត់ ឬធ្វើឱ្យខូចរូបរាងជាលិកាទន់ក្នុងមាត់

នៅពេលយកចេញពីមាត់ វាមិនត្រូវផ្លាស់ប្តូររូបរាងឡើយ

គ្មានម្សៅមួយណាដែលល្អឥតខ្ចោះទេ ប៉ុន្តែសំរាប់ការប្រើប្រាស់ខុសៗគ្នា ម្សៅផ្សេងគ្នា អាចយកជាការបានច្រើន។

**Impression compound** ជាម្សៅរឹង ដែលទន់ពេលត្រូវទឹកក្តៅ ហើយនឹងរឹងពេលដាក់ចូលក្នុងមាត់--វាមិនអាចប្រើនៅពេលដែលមានធ្មេញនោះទេ ដោយសារវាមិនមានភាពយឺត។

**Plaster of Paris** ជាម្សៅដែលរឹងខ្លាំងពេលស្ងួត គេលាយវាជាមួយទឹក -- វាមិនអាចប្រើយកពុម្ពពេលមានធ្មេញទេ។ ម្សៅទាំងអស់នេះ ត្រូវបានប្រើដោយទន្តពេទ្យជំនាញខាងបង្កើតធ្មេញសិ្ទតប៉ុណ្ណោះ។

**Alginate** ជាម្សៅខាំពុម្ពដែលគេនិយមប្រើជាងគេ។ គេប្រើវាដោយលាយជាមួយទឹកដែលមានបរិមាណសមស្រប ជាមួយនឹងអង្គធាតុរាវច្បាស់លាស់ ដើម្បីបាននូវម្សៅទន់ នៃ calcium alginate ដែលនឹងស្ងួតជាម្សៅរឹងក្នុងរយៈពេល ១-២ នាទី។



ប្រអប់ alginate ដែលមានគំរបជិត ត្រូវតែត្រឡប់ ពីរដងដើម្បីកុំអោយម្សៅណែនពេក។ស្លាបព្រាត្រូវបានប្រើដើម្បីវាល់ម្សៅនិងត្រូវប្រុងប្រយ័ត្ន មិនត្រូវសង្កត់ម្សៅអោយចូលក្នុងស្លាបព្រាទេ។ សំរាប់ម្សៅមួយស្លាបព្រា បរិមាណទឹក ២០-២៤ដឺក្រេ គឺត្រូវវាស់ដោយប្រុងប្រយ័ត្ន។

ប្រដាប់យកពុម្ពដែលសក្តិសម គួរតែត្រៀមជាស្រេច ហើយអាចត្រូវការការសិ្ទតមួយចំនួន ដើម្បីលាប ថ្វីបើប្រដាប់យកពុម្ពនោះមានប្រហោងក៏ដោយ ដើម្បីទប់ alginate ដែលរឹងនោះអោយជាប់នឹង ប្រដាប់យកពុម្ព។

ទឹកត្រូវបានបន្ថែមទៅម្សៅក្នុងចានទទន់ ហើយ ត្រូវលាយបញ្ចូលគ្នាយ៉ាងម៉ត់ចត់ដោយ spatula ជ័រ រហូតបានល្បាយដូចក្រែមរលោងដោយមិនមានដុំ រឺ ពពុះ បន្ទាប់មកដាក់វាទៅក្នុងប្រដាប់យកពុម្ព ដោយសង្កត់ alginate បន្តិច។

រយៈពេលកករឹងរបស់ alginate អាស្រ័យលើ សីតុណ្ហភាពរបស់ទឹក។ សីតុណ្ហភាពកាន់តែខ្ពស់ alginate នឹងកាន់តែរឹងលឿន។ ទឹកកាន់តែត្រជាក់ នោះ alginate នឹងត្រូវការពេលកាន់តែយូរដើម្បីរឹង។ ប្រសិនបើម្សៅច្រើនពេក នោះល្បាយម្សៅខាប់នោះមិនហូរជុំវិញធ្មេញទេ។ ប្រសិនបើ ម្សៅតិចពេក នោះល្បាយនោះ នឹងរាវខ្លាំង ហើយនឹងហូរចូលក្នុងបំពង់កអ្នកជំងឺ។

នៅពេល alginate រឹង ហើយបានដកចេញពីមាត់អ្នកជំងឺ គួរតែលាងជំរះជាមួយទឹកត្រជាក់ ដើម្បីលាងទឹកមាត់ចេញ។ បន្ទាប់មក វាគួរតែសំលាប់មេរោគ ដោយដាក់ត្រាំក្នុង Sodium Hypochloride បន្ទាប់មកលាងម្តងទៀត និង រុំវាជាមួយកំប្រេះសើម ហើយ ដាក់ចូលក្នុងថង់ប្លាស្ទិចបិតជិត។ Alginate អាចផ្លាស់ប្តូររូបរាងបន្ទាប់ពីវារឹង ដោយការបាត់បង់ជាតិទឹក ឬ ដោយការស្រូបជាតិទឹកពីមជ្ឈដ្ឋានជុំវិញ។



**Impression paste or Zinc Oxide Eugenol paste** ជារឿយៗ ត្រូវបានគេប្រើសំរាប់អ្នកជំងឺដែលគ្មានធ្មេញ សំរាប់យកពុម្ពចុងក្រោយ។ វាមិនមែនជាសំភារៈយកពុម្ពដែលយឺតនោះទេ ហើយ វាមិនអាចយកមកប្រើ នៅពេលនៅមានធ្មេញឡើយ។ បរិមាណម្សៅស្មើគ្នា ត្រូវបានវាស់យកមក។ Individual tray (ប្រដាប់យកពុម្ពធ្វើឡើងសំរាប់បុគ្គលម្នាក់ៗ) សំរាប់អ្នកជំងឺនោះ ត្រូវបានកែតំរូវនៅត្រង់គែមៗដោយប្រើ Greenstick compound។ វាត្រូវបានលាយយ៉ាងម៉ត់ចត់ ដោយប្រើ spatula ដែក នៅលើក្រដាសធំមួយ រហូតដល់ពណ៌ម្សៅស និង ពណ៌ត្នោតបាត់រូបរាង។ Vaseline ត្រូវលាបលើបបូរមាត់អ្នកជំងឺ ដោយសារម្សៅយកពុម្ពនេះ ស្អិតណាស់ ហើយ វាពិបាកយកចេញ ពីបបូរមាត់អ្នកជំងឺ។

នៅពេលរឹង Zinc Oxide impression past គឺមានលំនឹង ហើយមិនផ្លាស់ប្តូររូបរាងជាមួយសំណើមទេ។



**Elastomer** គឺជាម្សៅយកពុម្ពប្រភេទ rubber based រឺ Silicone ដែលយឺតបំផុត ហើយមិនរហែកដោយស្រួលឡើយនៅកន្លែងស្តើង។ វាមាន Heavy duty (putty) ដែលអោយការយកពុម្ពនោះពុំសូវល្អិតល្អន់ទេ និង ម្សៅម៉ត់ត្រូវបានបាញ់តាមសឺរ៉ាំងជុំវិញធ្មេញ ឬ នៅក្នុងពុម្ពធ្មេញ putty ដែលបានយករួចហើយពុម្ពធ្មេញនោះត្រូវបានយកម្តងទៀត ដើម្បីទទួលបានភាពល្អិតល្អន់បំផុតរបស់ធ្មេញ។ ជាធម្មតា វាត្រូវបានគេប្រើសំរាប់ ធ្មេញស្អិតធ្វើពីលោហៈ រឺ crown និង bridge ។

បន្ទាប់ពីសំលាប់មេរោគរួច ពុម្ពធ្មេញដែលយកបាននោះអាចបញ្ជូនតាមប្រៃសណីយ៍ ហើយ វានឹងរក្សាទំហំបានរយៈពេលយូរ។